# មូលដ្ឋានគ្រឹះនៃព្រះអភិធម្ម

## ចិត្តបរមត្ថ ១២១ ដួង

- ❖ កាមាវចរភូមិ ៥៤ ដួង
- ❖ រូបាវចរភូមិ ១៥ ដួង
- ❖ អរូបាវចរភូមិ ១២ ដួង
- ❖ លោកុត្តរភូមិ ៨ ឬ៤០ ដួង

### ❖ កាមាវចរភូមិ ៥៤ ដួង

- ➢ អកុសលចិត្ត ១២ ដួង
- ➢ អហេតុកចិត្ត ១៨ ដួង
- ➢ កាមាវចរសោភណចិត្ត២៤ដួង

## ➢ អកុសលចិត្ត ១២ ដួង

- លោភមូលចិត្ត ៨ ដួង
- ទោសមូលចិត្ត ២ ដួង
- មោហមូលចិត្ត ២ ដួង

### • លោភមូលចិត្ត ៨ ដួង

**១.សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រកបដោយមិច្ឆាទិដ្ឋិ (មិច្ឆាទិដ្ឋិទាំងអស់) មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃបបួលដឹកនាំ ។

**២.សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ មានការបបួលដឹកនាំពីអ្នកដទៃ ។

**៣.សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃបបួលដឹកនាំ ។

**៤.សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៥.ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃ បបួលដឹកនាំ ។

**៦.ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ ។

**៧.ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃបបួលដឹកនាំ ។

**៨.ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ ។**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ ។

- **ទោសមូលចិត្ត ២ ដួង**

**១.ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ ។**

ទោសមូលចិត្ត ប្រព្រឹត្តទៅជាមួយទោមនស្សវេទនា ប្រកបដោយសេចក្តីថ្នាំងថ្នាក់ មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃបបួលដឹកនាំ ។

**១.ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ ។**

ទោសមូលចិត្ត ប្រព្រឹត្តទៅជាមួយទោមនស្សវេទនា ប្រកបដោយសេចក្តីថ្នាំងថ្នាក់ មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ ។

## • មោហមូលចិត្ត ២ ដួង

**១.ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ**

មោហមូលចិត្ត ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា ប្រកបជាមួយវិចិកិច្ឆា (សេចក្ដីសង្ស័យ) ។

**២.ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ**

មោហមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបជាមួយឧទ្ធច្ចៈ (រវើរវាយ) ។

## ➢ អហេតុកចិត្ត ១៨ ដួង

- អកុសលវិបាកចិត្ត ៧ ដួង
- អហេតុកកុសលវិបាក ៨ ដួង
- អហេតុកកិរិយាចិត្ត ៣ ដួង

## • អកុសលវិបាកចិត្ត ៧ ដួង

**១.ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណអកុសលវិបាកចិត្តំ ។**

ចក្ខុវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា(មានការឃើញរូបមិនល្អ)។

**២.ឧបេក្ខាសហគតំ សោតវិញ្ញាណ អកុសលវិបាកចិត្តំ ។**

សោតវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា(មានការឮសំឡេងមិនល្អ)។

**៣.ឧបេក្ខាសហគតំ ឃានវិញ្ញាណ អកុសលវិបាកចិត្តំ ។**

ឃានវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា (មានការដឹងក្លិនមិនល្អ) ។

**៤.ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណអកុសលវិបាកចិត្តំ ។**

ជិវ្ហាវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (មានការដឹងរសមិនល្អ)។

**៥.ទុក្ខសហគតំ កាយវិញ្ញាណំ អកុសលវិបាកចិត្តំ ។**

កាយវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយទុក្ខវេទនា មានការដឹងផោដ្ឋព្វៈមិនល្អ ។

**៦.ឧបេក្ខាសហគតំ មនោធាតុ អកុសលវិបាកចិត្តំ ។**

មនោធាតុដែលជា អកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា(មានការទទួលដឹងនូវអារម្មណ៍មិនល្អពីបញ្ចវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម) មនោធាតុដឹងអារម្មណ៍បាន ៥ ។

**៧.ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អកុសលវិបាកចិត្តំ ។**

មនោធាតុវិញ្ញាណធាតុ ដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា មានការដឹងអារម្មណ៍មិនល្អបានទាំង ៦ (ណាមួយ) ។

- **អហេតុកកុសលវិបាកចិត្ត ៨ ដួង**

**១.ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណ កុសល-វិបាកចិត្តំ ។**

ចក្ខុវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា(ឃើញរូបល្អ) ។

**២.ឧបេក្ខាសហគតំ សោតវិញ្ញាណ កុស-លវិបាកចិត្តំ ។**

សោតវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា (ឮសំឡេងល្អ) ។

**៣.ឧបេក្ខាសហគតំ ឃានវិញ្ញាណ កុសលវិបាកចិត្តំ ។**

ឃានវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា (ដឹងក្លិនល្អ) ។

**៤.ឧបេក្ខា សហគតំ ជិវ្ហាវិញ្ញាណកុសល-វិបាកចិត្តំ ។**

ជិវ្ហាវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ដឹងរសល្អ)។

**៥.សុខសហគតំ កាយវិញ្ញាណកុសល-វិបាកចិត្តំ ។**

កាយវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយសុខវេទនា (ដឹងផោដ្ឋព្វៈល្អ) ។

**៦.ឧបេក្ខាសហគតំ មនោធាតុកុសល វិបាកចិត្តំ ។**

មនោធាតុដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ដឹងនូវអារម្មណ៍ល្អពីបញ្ចវិញ្ញាណ) ។

**៧.សោមនស្សសហគតំ មនោវិញ្ញាណ-ធាតុអហេតុកកុសលវិបាកចិត្តំ ។**

មនោវិញ្ញាណធាតុ ដែលជាអហេតុកកុសលវិបាក ប្រព្រឹត្តទៅជាមួយ សោមនស្សវេទនា ដឹងអារម្មណ៍ល្អ (អារម្មណ៍ទាំង ៦ ណាមួយ) ។

**៨.ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុកុសលវិបាកចិត្តំ ។**

មនោវិញ្ញាណធាតុ ដែលជាអហេតុកកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ដឹងអារម្មណ៍ល្អ (អារម្មណ៍ទាំង ៦ ណាមួយ) ។

## • អហេតុកកិរិយាចិត្ត ៣ ដួង

**១.ឧបេក្ខាសហគតំ មនោធាតុកិរិយាចិត្តំ ។**

មនោធាតុដែលជាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ។

**២.ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្តំ ។**

មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ។

**៣.សោមនស្សសហគតំ មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្តំ ។**

មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ។

## ➢ កាមាវចរសោភណចិត្ត ២៤ ដួង

- *មហាកុសលចិត្ត ៨ ដួង*
- *មហាវិបាកចិត្ត ៨ ដួង*
- *មហាកិរិយាចិត្ត ៨ ដួង*

### • មហាកុសលចិត្ត ៨ ដួង

**១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ ។**

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយ សោមនស្ស-វេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ ។**

មហាកុសលចិត្តប្រព្រឹត្តទៅ ជាមួយ សោមនស្ស
វេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើត
ឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ ។**

មហាកុសលចិត្តប្រព្រឹត្តទៅ ជាមួយសោមនស្ស-
វេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើត
ឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ ។**

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-
វេទនា ប្រាសចាកបញ្ញាមានកម្លាំងខ្សោយកើតឡើង
ដោយមានអ្នកដទៃបបួលដឹកនាំ។

**៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ ។**

មហាកុសលចិត្តប្រព្រឹត្តទៅ ជាមួយឧបេក្ខា-វេទនាប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ។**

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខា-វេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ ។**

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខា-វេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ។**

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

- **មហាវិបាកចិត្ត ៨ ដួង**

**១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ ។**

មហាវិបាកចិត្តប្រព្រឹត្តទៅ ជាមួយសោមនស្ស-វេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំមហាវិបាកចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

## • មហាកិរិយាចិត្ត ៨ ដួង

**១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ។

**៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ ។**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

## ➢ រូបាវចរភូមិ ១៥ ដួង

- *រូបាវចរកុសលចិត្ត ៥ ដួង*
- *រូបាវចរវិបាកចិត្ត ៥ ដួង*
- *រូបាវចរកិរិយាចិត្ត ៥ ដួង*

### • រូបាវចរកុសលចិត្ត៥ ដួង

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋម-ជ្ឈានកុសលចិត្តំ ។**

បឋមជ្ឈានកុសលចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានកុសលចិត្តំ ។**

ទុតិយជ្ឈានកុសលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន កុសលចិត្តំ ។**

តតិយជ្ឈានកុសលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន កុសល-ចិត្តំ ។**

ចតុត្ថជ្ឈានកុសលចិត្តប្រកបដោយសុខៈនិងឯកគ្គតា។

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន កុសលចិត្តំ ។**

បញ្ចមជ្ឈានកុសលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

- **រូបាវចរវិបាកចិត្ត ៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានវិបាកចិត្តំ ។**

បឋមជ្ឈានវិបាកចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានវិបាកចិត្តំ ។**

ទុតិយជ្ឈានវិបាកចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈានវិបាកចិត្តំ ។**

តតិយជ្ឈានវិបាកចិត្ត ប្រកបដោយ បីតិ សុខៈ និងឯកគ្គតា។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈានវិបាក-ចិត្តំ ។**

ចតុត្ថជ្ឈានវិបាកចិត្តប្រកបដោយសុខៈ និងឯកគ្គតា។

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈានវិបាកចិត្តំ ។**

បញ្ចមជ្ឈានវិបាកចិត្ត ប្រកបដោយឧបេក្ខា និងឯកគ្គតា ។

- **រូបាវចរកិរិយាចិត្ត ៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតាសហិតំ បឋមជ្ឈានកិរិយាចិត្តំ ។**

បឋមជ្ឈានកិរិយាចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានកិរិយាចិត្តំ ។**

ទុតិយជ្ឈានកិរិយាចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន កិរិយាចិត្តំ ។**

តតិយជ្ឈានកិរិយាចិត្ត ប្រកបដោយ បីតិ សុខៈ និងឯកគ្គតា។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈានកិរិយា-ចិត្តំ ។**

ចតុត្ថជ្ឈានកិរិយាចិត្តប្រកបដោយសុខៈនិងឯកគ្គតា។

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន កិរិយាចិត្តំ ។**

បញ្ចមជ្ឈានកិរិយាចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

➢ **អរូបាវចរភូមិ ១២ ដួង**

- *អរូបាវចរកុសលចិត្ត ៤ ដួង*
- *អរូបាវចរវិបាកចិត្ត ៤ ដួង*
- *អរូបាវចរកិរិយាចិត្ត ៤ ដួង*

## • អរូបាវចរកុសលចិត្ត ៤ ដួង

**១.ឧបេក្ខេកគ្គតា សហិតំ អាកាសានញ្ចាយ-តនកុសលចិត្តំ ។**

អាកាសានញ្ចាយតនកុសលចិត្ត១ ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯក-គ្គតា ។

**២.ឧបេក្ខេកគ្គតា សហិតំ វិញ្ញាណញ្ចាយ-តនកុសលចិត្តំ ។**

វិញ្ញាណញ្ចាយតនកុសលចិត្ត១ ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯក-គ្គតា ។

**៣.ឧបេក្ខេកគ្គតា សហិតំ អាកិញ្ចញ្ញាយតនកុសលចិត្តំ ។**

អាកិញ្ចញ្ញាយតនកុសលចិត្ត ១ ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

**៤.ឧបេក្ខេកគ្គតា សហិតំ នេវសញ្ញានាស-ញ្ញាយតនកុសលចិត្តំ ។**

នេវសញ្ញានាសញ្ញាយតនកុសលចិត្ត១ ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯក-គ្គតា ។

- **អរូបាវចរវិបាកចិត្ត ៤ ដួង**

**១.ឧបេក្ខេកគ្គតា សហិតំ អាកាសានញ្ចាយ-តនវិបាកចិត្តំ ។**

អាកាសានញ្ចាយតនវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯក-គ្គតា ។

**២.ឧបេក្ខេកគ្គតា សហិតំ វិញ្ញាណញ្ចាយ-តនវិបាកចិត្តំ ។**

វិញ្ញាណញ្ចាយតនវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

**៣.ឧបេក្ខេកគ្គតា សហិតំ អាកិញ្ចញ្ញាយតន វិបាកចិត្តំ ។**

អាកិញ្ចញ្ញាយតនវិបាកចិត្ត ដែលកើតឡើងព្រម ដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

**៤.ឧបេក្ខេកគ្គតា សហិតំ នេវសញ្ញានាស-ញ្ញាយតនវិបាកចិត្តំ ។**

នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ដែលកើត ឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯក គ្គតា ។

- **អរូបាវចរកិរិយាចិត្ត ៤ ដួង**

**១.ឧបេក្ខេកគ្គតា សហិតំ អាកាសានញ្ចាយ-តនកិរិយាចិត្តំ ។**

អាកាសានញ្ចាយតនកិរិយាចិត្ត ដែលកើតឡើង ព្រមដោយអង្គឈាន២ គឺឧបេក្ខានិងឯកគ្គតា។

**២.ឧបេក្ខេកគ្គតា សហិតំ វិញ្ញាណញ្ចាយ-តនកិរិយាចិត្តំ ។**

វិញ្ញាណញ្ចាយតនកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

**៣.ឧបេក្ខេកគ្គតា សហិតំ អាកិញ្ចញ្ញាយតនកិរិយាចិត្តំ ។**

អាកិញ្ចញ្ញាយតនកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

**៤.ឧបេក្ខេកគ្គតា សហិតំ នេវសញ្ញានាស-ញ្ញាយតនកិរិយាចិត្តំ។**

នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

- **លោកុត្តរចិត្ត ៤0 ដួង**
  - *លោកុត្តរមគ្គជ្ឈានចិត្ត ២០ ដួង*
  - *លោកុត្តរវិបាកជ្ឈានចិត្ត ២០ ដួង*
  - **លោកុត្តរមគ្គជ្ឈានចិត្ត២0 ដួង**

- *សោតាបត្តិមគ្គជ្ឈានចិត្ត ៤ ដួង*
- *សកទាគាមិមគ្គជ្ឈានចិត្ត ៤ ដួង*
- *អនាគាមិមគ្គជ្ឈានចិត្ត ៤ ដួង*
- *អរហត្តមគ្គជ្ឈានចិត្ត ៤ ដួង*

- **សោតាបត្តិមគ្គជ្ឈានចិត្ត៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានសោតាបត្តិមគ្គចិត្តំ។**

បឋមជ្ឈានសោតាបត្តិមគ្គចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈនិងឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានសោតាបត្តិមគ្គចិត្តំ ។**

ទុតិយជ្ឈានសោតាបត្តិមចិត្ត ប្រកបដោយវិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន សោតាបត្តិមគ្គចិត្តំ។**

តតិយជ្ឈានសោតាបត្តិមគ្គចិត្ត ប្រកបដោយ បីតិ សុខៈ និងឯកគ្គតា ។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន សោតា-បត្តិមគ្គចិត្តំ។**

ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្ត ប្រកបដោយ សុខៈ និងឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន-សោតាបត្តិមគ្គចិត្តំ ។**

បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្ត ប្រកបដោយឧបេក្ខា និង ឯកគ្គតា។

➢ **សកទាគាមិមគ្គជ្ឈានចិត្ត ៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានសកទាគាមិមគ្គចិត្តំ។**

បឋមជ្ឈានសកទាគាមិមគ្គចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈាន សកទាគាមិមគ្គចិត្តំ។**

ទុតិយជ្ឈានសកទាគាមិមគ្គចិត្តប្រកបដោយវិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន សកទាគាមិមគ្គចិត្តំ ។**

តតិយជ្ឈានសកទាគាមិមគ្គចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេ កគ្គតា សហិតំ ចតុត្ថជ្ឈាន សកទាគាមិមគ្គចិត្តំ។**

ចតុត្ថជ្ឈានសកទាគាមិមគ្គចិត្ត ប្រកបដោយសុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេ កគ្គតា សហិតំ បញ្ចមជ្ឈាន សកទាគាមិមគ្គចិត្តំ។**

បញ្ចមជ្ឈានសកទាគាមិមគ្គចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

- **អនាគាមិមគ្គជ្ឈានចិត្ត ៥ ដួង**

**១.វិតក្កៈ វិចារៈ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈាន អនាគាមិមគ្គចិត្តំ។**

បឋមជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**២.វិចារៈ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈាន អនាគាមិមគ្គចិត្តំ ។**

ទុតិយជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន អនាគាមិមគ្គចិត្តំ ។**

តតិយជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយបីតិសុខៈ និងឯកគ្គតា ។

**៤.សុខេ កគ្គតា សហិតំ ចតុត្ថជ្ឈាន-អនាគាមិមគ្គចិត្តំ ។**

ចតុត្ថជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយ សុខៈ និងឯកគ្គត្តា ។

**៥.ឧបេក្ខេ កគ្គតា សហិតំ បញ្ចមជ្ឈាន អនាគាមិមគ្គចិត្តំ ។**

បញ្ចមជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយឧបេក្ខា និង ឯកគ្គតា ។

➢ **អរហត្តមគ្គជ្ឈានចិត្ត ៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានអរហត្តមគ្គចិត្តំ ។**

បឋមជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានអរហត្តមគ្គចិត្តំ ។**

ទុតិយជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន អរហត្តមគ្គចិត្តំ ។**

តតិយជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន អរហត្ត មគ្គចិត្តំ ។**

ចតុត្ថជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ សុខៈ និងឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន អរហត្តមគ្គចិត្តំ ។**

បញ្ចមជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

- **លោកុត្តរវិបាកជ្ឈានចិត្ត២០ ដួង**

- *សោតាបត្តិផលជ្ឈានចិត្ត ៥ ដួង*
- *សកទាគាមិផលជ្ឈានចិត្ត ៥ ដួង*

- *អនាគាមិផលជ្ឈាន ៥ ដួង*
- *អរហត្តផលជ្ឈានចិត្ត ៥ ដួង*

- **សោតាបត្តិផលជ្ឈានចិត្ត ៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានសោតាបត្តិផលចិត្តំ។**

បឋមជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានសោតាបត្តិផលចិត្តំ ។**

ទុតិយជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន សោតាបត្តិផលចិត្តំ។**

តតិយជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេ កគ្គតា សហិតំ ចតុត្ថជ្ឈាន សោតា-បត្តិផលចិត្តំ។**

ចតុត្ថជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយសុខៈ និងឯកគ្គតា ។

**៥.ឧបេក្ខេ កគ្គតា សហិតំ បញ្ចមជ្ឈាន សោតាបត្តិផលចិត្តំ ។**

បញ្ចមជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

- **សកទាគាមិផលជ្ឈានចិត្ត ៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានសកទាគាមិផលចិត្តំ។**

បឋមជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានសកទាគាមិផលចិត្តំ។**

ទុតិយជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន សកទាគាមិផលចិត្តំ ។**

តតិយជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន សកទាគាមិផលចិត្តំ។**

ចតុត្ថជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេ កគ្គតា សហិតំ បញ្ចមជ្ឈាន សកទាគាមិផលចិត្តំ។**

បញ្ចមជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

- **អនាគាមិផលជ្ឈានចិត្ត៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈាន អនាគាមិផលចិត្តំ ។**

បឋមជ្ឈានអនាគាមិផលចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈាន អនាគាមិផលចិត្តំ ។**

ទុតិយជ្ឈានអនាគាមិផលចិត្ត ប្រកបដោយវិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន អនាគាមិផលចិត្តំ ។**

តតិយជ្ឈានអនាគាមិផលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន អនាគាមិផលចិត្តំ ។**

ចតុត្ថជ្ឈានអនាគាមិផលចិត្ត ប្រកបដោយសុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន អនាគាមិផលចិត្តំ ។**

បញ្ចមជ្ឈានអនាគាមិផលចិត្ត ប្រកបដោយ ឧបេក្ខា និងឯកគ្គតា ។

- **អរហត្តផលជ្ឈានចិត្ត ៥ ដួង**

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានអរហត្តផលចិត្តំ ។**

បឋមជ្ឈានអរហត្តផលចិត្ត ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយ-ជ្ឈានអរហត្តផលចិត្តំ ។**

ទុតិយជ្ឈានអរហត្តផលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា។

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈាន អរហត្តផលចិត្តំ ។**

តតិយជ្ឈានអរហត្តផលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតា សហិតំ ចតុត្ថជ្ឈានអរហត្ត-ផលចិត្តំ ។**

ចតុត្ថជ្ឈានអរហត្តផលចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន អរហត្តផលចិត្តំ ។**

បញ្ចមជ្ឈានអរហត្តផលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

# ចេតសិកបរមត្ថ ៥២ ប្រភេទ

- អញ្ញសមានាចេតសិក ១៣
- អកុសលចេតសិក ១៤
- សោភណាចេតសិក ២៥

➢ **អញ្ញសមានាចេតសិក ១៣**

➢ *សព្វចិត្តសាធារណចេតសិក ៧*

➢ *បកិណ្ណកចេតសិក ៦*

➢ ***សព្វចិត្តសាធារចេតសិក៧ ប្រភេទ***

**១.ផស្សចេតសិក**

ធម្មជាតិដែលប៉ះនូវអារម្មណ៍។

**២.វេទនាចេតសិក**

ធម្មជាតិដែលសោយនូវអារម្មណ៍។

**៣.សញ្ញាចេតសិក**

ធម្មជាតិដែលសំគាល់នូវអារម្មណ៍។

**៤.ចេតនាចេតសិក**

ធម្មជាតិដែលចាត់ចែងអារម្មណ៍ ។

**៥.ឯកគ្គតាចេតសិក**

ធម្មជាតិដែលផ្គងចិត្តឲ្យមានអារម្មណ៍តែ ១។

**៦.ជីវិតិន្ទ្រិយចេតសិក**

ធម្មជាតិដែលរក្សាសម្បយុត្តធម៌។

**៧.មនសិការចេតសិក**

ធម្មជាតិដែលធ្វើទុកក្នុងចិត្ត ។

## ➢ បកិណ្ណកចេតសិក ៦ ប្រភេទ

**១.វិតក្កចេតសិក**

ធម្មជាតិដែលត្រិះរិះនូវអារម្មណ៍ ។

**២.វិចារចេតសិក**

ធម្មជាតិដែលពិចារណានូវអារម្មណ៍ ។

**៣.អធិមោក្ខចេតសិក**

ធម្មជាតិដែលចុះស៊ុបក្នុងអារម្មណ៍ ។

**៤.វីរិយចេតសិក**

ធម្មជាតិដែលសេចក្តីព្យាយាម ។

**៥.បីតិចេតសិក**

ធម្មជាតិដែលឆ្អែតក្នុងកាយចិត្ត ។

**៦.ឆន្ទចេតសិក**

ធម្មជាតិដែលពេញចិត្តក្នុងអារម្មណ៍ ។

- ***អកុសលចេតសិក ១៤ ប្រភេទ***
  - មោចតុក ៤
  - លោតិក ៣
  - ដោចតុក ៤
  - ថីទុក ២
  - ឯកាវិចិកិច្ឆា ១
    - ***មោចតុក ៤***

**១.មោហចេតសិក**

ធម្មជាតិដែលវង្វេងក្នុងអារម្មណ៍ ។

**២.អហិរិកចេតសិក**

ធម្មជាតិដែលមិនខ្មាស់បាប ។

**៣.អនោត្តប្បចេតសិក**

ធម្មជាតិដែលមិនតក់ស្លុតក្នុងបាប ។

**៤.ឧទ្ធច្ចចេតសិក**

ធម្មជាតិដែលរវើររវាយក្នុងអារម្មណ៍ ។

- **លោតិក ៣**

**១.លោភចេតសិក**

ធម្មជាតិដែលជាប់ជំពាក់ក្នុងអារម្មណ៍ ។

**២.ទិដ្ឋិចេតសិក**

ធម្មជាតិដែលយល់ខុស ។

**៣.មានចេតសិក**

ធម្មជាតិដែលរឹងត្អឹង ។

- **ទោចតុក ៤**

**១.ទោសចេតសិក**

ធម្មជាតិដែលប្រទូសក្នុងអារម្មណ៍ ។

**២.ឥស្សាចេតសិក**

ធម្មជាតិដែលច្រណែននិន្ទា ។

**៣.មច្ឆរិយចេតសិក**

ធម្មជាតិដែលកំណាញ់ ។

**៤.កុក្កុច្ចចេតសិក**

ធម្មជាតិដែលក្តៅក្រហាយ ។

- **ថីទុក ២**

**១.ថីនចេតសិក**

ធម្មជាតិដែលរួញរា ។

**២.មិទ្ធចេតសិក**

ធម្មជាតិដែលងោកងុយ ។

- **ឯកវិចិកិច្ឆា ១**

**១.វិចិកិច្ឆាចេតសិក**

ធម្មជាតិដែលការសង្ស័យ ។

➢ **សោភណចេតសិក ២៥**

**១.សទ្ធាចេតសិក**

ធម្មជាតិដែលជឿកម្មផល ។

**២.សតិចេតសិក**

ធម្មជាតិដែលរលឹកដឹងខុសត្រូវ ។

**៣.ហិរិចេតសិក**

ធម្មជាតិដែលខ្មាស់បាប ។

**៤.ឱត្តប្បចេតសិក**

ធម្មជាតិដែលតក់ស្លុតក្នុងអំពើបាប ។

**៥.អលោភចេតសិក**

ធម្មជាតិដែលមិនជាប់ជំពាក់ ។

**៦.អទោសចេតសិក**

ធម្មជាតិដែលមិនប្រទូស្ត ។

**៧.តត្រមជ្ឈត្តតាចេតសិក**

ធម្មជាតិដែលសម្លឹងជាកណ្តាល ។

**៨.កាយបស្សទ្ធិចេតសិក**

ធម្មជាតិដែលស្ងប់កាយ ។

**៩.ចិត្តបស្សទ្ធិចេតសិក**

ធម្មជាតិដែលស្ងប់ចិត្ត ។

**១០.កាយលហុតាចេតសិក**

ធម្មជាតិដែលស្រាលកាយ ។

**១១.ចិត្តលហុតាចេតសិក**

ធម្មជាតិដែលស្រាលចិត្ត ។

**១២.កាយមុទុតាចេតសិក**

ធម្មជាតិដែលទន់ភ្លន់កាយ ។

**១៣.ចិត្តមុទុតាចេតសិក**

ធម្មជាតិដែលទន់ភ្លន់ចិត្ត ។

**១៤.កាយកម្មញ្ញតាចេតសិក**

ធម្មជាតិដែលកាយគួរដល់ការងារ ។

**១៥.ចិត្តកម្មញ្ញតាចេតសិក**

ធម្មជាតិដែលចិត្តគួរដល់ការងារ ។

**១៦.កាយបាគុញ្ញតាចេតសិក**

ធម្មជាតិដែលកាយស្ទាត់ជំនាញ ។

**១៧.ចិត្តបាគុញ្ញតាចេតសិក**

ធម្មជាតិដែលចិត្តស្ទាត់ជំនាញ ។

**១៨.កាយុជុកតាចេតសិក**

ធម្មជាតិដែលកាយត្រូវត្រង់ ។

**១៩.ចិត្តុជុកតាចេតសិក**

ធម្មជាតិដែលចិត្តត្រូវត្រង់ ។

## វិរតិចេតសិក ៣

**២០.សម្មាវាចាចេតសិក**

សំដីដែលប្រពៃ ។

**២១.សម្មាកម្មន្តចេតសិក**

ការងារដែលប្រពៃ ។

**២២.សម្មាអាជីវចេតសិក**

អាជីវៈដែលប្រពៃ ។

## អប្បមញ្ញាចេតសិក ២

**២៣.ករុណាចេតសិក**

ធម្មជាតិដែលអាណិតអាសូរ ។

**២៤.មុទិតាចេតសិក**

ការទន់ភ្លន់តាម ។

# បញ្ញិន្ទ្រិយចេតសិក ១

## ២៥.បញ្ញាចេតសិក

ធម្មជាតិដែលចេះដឹងគឺ បញ្ញា ។

# <u>ចិត្តបរមត្ថ</u> <u>៨៩</u> ឬ <u>១២១</u> ដួង

## ១.កាមាវចរភូមិ ៥៤ ដួង

### ១/១.លោភមូលចិត្ត ៨ ដួង



## ១/២.ទោសមូលចិត្ត ២ ដួង




## ១/៣.មោហមូលចិត្ត ២ ដួង




## ១/៤.អកុសលវិបាចិត្ត ៧ ដួង



## ១/៥.អហេតុកកុសលវិបាកចិត្ត៨ ដួង

| | | | |
|---|---|---|---|
| ឧ | ចក្ខុ | កុ | ៧ |
| ឧ | សោត | កុ | ៧ |
| ឧ | ឃាន | កុ | ៧ |
| ឧ | ជិវ្ហា | កុ | ៧ |
| សុខ | កាយ | កុ | ៧ |
| ឧ | មនោ | កុ | ១០ |
| សោ | ម.វិ | កុ | ១១ |
| ឧ | ម.វិ | កុ | ១០ |

## ១/៦.អហេតុកកិរិយាចិត្ត ៣ ដួង

| | | | |
|---|---|---|---|
| ឧ | មនោ | កិ | ១០ |
| ឧ | ម.វិ | កិ | ១១ |
| សោ | ម.វិ | កិ | ១២ |

## ១/៧.មហាកុសលចិត្ត ៨ ដួង

| | | | |
|---|---|---|---|
| សោ | ញ.ស | អ | ៣៨ |
| សោ | ញ.ស | ស | ៣៨ |
| សោ | ញ.វិ | អ | ៣៧ |
| សោ | ញ.វិ | ស | ៣៧ |
| ឧ | ញ.ស | អ | ៣៧ |
| ឧ | ញ.ស | ស | ៣៧ |
| ឧ | ញ.វិ | អ | ៣៦ |
| ឧ | ញ.វិ | ស | ៣៦ |

## ១/៨.មហាវិបាកចិត្ត ៨ ដួង




## ១/៩.មហាកិរិយាចិត្ត ៨ ដួង




# ២.រូបាវចរចិត្ត ១៥ ដួង

## ២/១.រូបាវចរកុសលចិត្ត ៥ ដួង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វិ.ឯ | ប.កុ | វិ..ឯ | ធុ.កុ | បី.ឯ | ត.កុ | សុ.ឯ | ច.កុ | ឧ.ឯ | ប..កុ |
| ស | ៣៥ | ស | ៣៤ | ស | ៣៣ | ស | ៣២ | ស | ៣០ |

## ២/២.រូបាវចរវិបាកចិត្ត ៥ ដួង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វិ.ឯ | ប.វិ | វិ..ឯ | ធុ.វិ | បី.ឯ | ត.វិ | សុ.ឯ | ច.វិ | ឧ.ឯ | ប..វិ |
| ស | ៣៥ | ស | ៣៤ | ស | ៣៣ | ស | ៣២ | ស | ៣០ |

## ២/៣.រូបាវចរកិរិយាចិត្ត ៥ ដួង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វិ.ឯ | ប.កិ | វិ..ឯ | ធុ.កិ | បី.ឯ | ត.កិ | សុ.ឯ | ច.កិ | ឧ.ឯ | ប..កិ |
| ស | ៣៥ | ស | ៣៤ | ស | ៣៣ | ស | ៣២ | ស | ៣០ |

# ៣.អរូប្បាវចរចិត្ត ១២ ដួង

## ៣/១.អរូបាវចរកុសលចិត្ត ៤ ដួង

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឧ.ឯ | អា.កុ | ឧ.ឯ | វិ.កុ | ឧ.ឯ | អា..កុ | ឧ.ឯ | នេ.កុ |
| ស | ៣០ | ស | ៣០ | ស | ៣០ | ស | ៣០ |

## ៣/២.អរូបាវចរវិបាកចិត្ត ៤ ដួង




## ៣/៣.អរូបាវចរកិរិយាចិត្ត ៤ ដួង




# ៤.លោកុត្តរភូមិ ៤០ ដួង

## ៤/១.សោតាបត្តិមគ្គចិត្ត ៥ ដួង



## ៤/២.សកទាគាមិមគ្គចិត្ត ៥ ដួង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ទិ.ឯ | ស.ក | ទិ..ឯ | ស.ក | បី.ឯ | ស.ក | សុ.ឯ | ស.ក | ឱ.ឯ | ស.ក |
| ស | ៣៦ | ស | ៣៥ | ស | ៣៤ | ស | ៣៣ | ស | ៣៣ |

## ៤/៣.អនាគាមិមគ្គចិត្ត ៥ ដួង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ទិ.ឯ | សម្បូ | ទិ..ឯ | សម្បូ | បី.ឯ | ទិប្បូ | សុ.ឯ | ទិប្បូ | ឱ.ឯ | ម.ទិ |
| ស | ៣៦ | ស | ៣៥ | ស | ៣៤ | ស | ៣៣ | ស | ៣៣ |

## ៤/៤.អរហត្តមគ្គចិត្ត ៥ ដួង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ទិ.ឯ | អរ.ម | ទិ..ឯ | អរ.ម | បី.ឯ | អរ.ម | សុ.ឯ | អរ.ម | ឱ.ឯ | អរ.ម |
| ស | ៣៦ | ស | ៣៥ | ស | ៣៤ | ស | ៣៣ | ស | ៣៣ |

## ៤/៥.សោតាបត្តិផលចិត្ត ៥ ដួង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ទិ.ឯ | ស.ផ | ទិ..ឯ | ស.ផ | បី.ឯ | ស.ផ | សុ.ឯ | ស.ផ | ឱ.ឯ | ស.ផ |
| ស | ៣៦ | ស | ៣៥ | ស | ៣៤ | ស | ៣៣ | ស | ៣៣ |

## ៤/៦.សកទាគាមិផលចិត្ត ៥ ដួង




## ៤/៧.អានាគាមិផលចិត្ត ៥ ដួង




## ៤/៨.អរហត្តផលចិត្ត ៥ ដួង




# អធិប្បាយអក្សរកាត់

| ល.រ | អក្សរកាត់ | អក្សរពេញ |
|---|---|---|
| ១ | កិ | កិរិយាចិត្ត |

| | | |
|---|---|---|
| ២ | កុ | កុសលចិត្ត |
| ៣ | ឃាន | ឃានវិញ្ញាណ |
| ៤ | ច.កុ | ចតុត្ថជ្ឈានកុសល |
| ៥ | ចក្ខុ | ចក្ខុវិញ្ញាណ |
| ៦ | ច.វិ | ចតុត្ថជ្ឈានវិបាក |
| ៧ | ជិវ្ហា | ជិវ្ហាវិញ្ញាណ |
| ៨ | ញា.វិ | ញាណវិប្បយុត្ត |
| ៩ | ញា.ស | ញាណសម្បយុត្ត |
| ១០ | ត.កិ | តតិយជ្ឈានកិរិយា |
| ១១ | ត.វិ | តតិយជ្ឈានវិបាក |
| ១២ | ទោ | ទោមនស្ស |
| ១៣ | ទុ.កិ | ទុតិយជ្ឈានកិរិយា |
| ១៤ | ទុក្ខ | ទុក្ខសហគត |
| ១៥ | នេ.កុ | នេវសញ្ញានាសញ្ញាកុសល |

| | | |
|---|---|---|
| ១៦ | នេ.វិ | នេវសញ្ញានាសញ្ញាវិបាក |
| ១៧ | ប.កិ | បឋមជ្ឈានកិរិយា |
| ១៨ | ប.វិ | បឋមជ្ឈានវិបាក |
| ១៩ | ប.កុ | បឋមជ្ឈានកុសល |
| ២០ | ប..កិ | បញ្ចមជ្ឈានកិរិយា |
| ២១ | ប..កុ | បញ្ចមជ្ឈានកុសល |
| ២២ | បដិ | បដិឃសម្បយុត្ត |
| ២៣ | ប..វិ | បញ្ចមជ្ឈានវិបាក |
| ២៤ | បី.ឯ | បីតិ រហូតដល់ ឯកគ្គតា |
| ២៥ | ម.វិ | មនោវិញ្ញាណធាតុ |
| ២៦ | មនោ | មនោធាតុ |
| ២៧ | វិ | វិបាក |
| ២៨ | វិ.កិ | វិញ្ញាណញ្ចាយតនកិរិយា |
| ២៩ | វិ.កុ | វិញ្ញាណញ្ចាយតនកុសល |

| | | |
|---|---|---|
| ៣០ | វិ.វិ | វិញ្ញាណញ្ចាយតនវិបាក |
| ៣១ | វិចិ | វិចិកិច្ឆា |
| ៣២ | វិប្ប | វិប្បយុត្ត |
| ៣៣ | វិ.ឯ | វិតក្ក រហូតដល់ ឯកគ្គតា |
| ៣៤ | វិ..ឯ | វិចារ រហូតដល់ ឯកគ្គតា |
| ៣៥ | ស | សសង្ខារិក |
| ៣៦ | សោ | សោមនស្ស |
| ៣៧ | សុខ | សុខសហាគតំ |
| ៣៨ | ស.ផ | សោត្តាបត្តិផល |
| ៣៩ | ស.ម | សោត្តាបត្តិមគ្គ |
| ៤០ | សម្ប | សម្បយុត្ត |
| ៤១ | សុ.ឯ | សុខ រហូតដល់ ឯកគ្គតា |
| ៤២ | សក.ផ | សកទាគាមិផល |
| ៤៣ | សក.ម | សកទាគាមិមគ្គ |

| | | |
|---|---|---|
| ៤៤ | អ | អសង្ខារិក |
| ៤៥ | អ.ផ | អនាគាមិផល |
| ៤៦ | អរ.ផ | អរហត្តផល |
| ៤៧ | អ.ម | អនាគាមិមគ្គ |
| ៤៨ | អរ.ម | អរហត្តមគ្គ |
| ៤៩ | អា..កិ | អាកិញ្ចញ្ញាយតនកិរិយា |
| ៥០ | អា..កុ | អាកិញ្ចញ្ញាយតនកុសល |
| ៥១ | អា..វិ | អាកិញ្ចញ្ញាយតនវិបាក |
| ៥២ | អា.កិ | អាកាសានញ្ចាយតនកិរិយា |
| ៥៣ | អា.កុ | អាកាសានញ្ចាយតនកុសល |
| ៥៤ | អា.វិ | អាកាសានញ្ចាយតនវិបាក |
| ៥៥ | ឧ | ឧបេក្ខា |
| ៥៦ | ឧ.ឯ | ឧបេក្ខា និង ឯកគ្គតា |
| ៥៧ | ឧទ្ធ | ឧទ្ធច្ចសម្បយុត្ត |

# អធិប្បាយសម្បយោគ
## សម្បយោគន័យសព្វចិត្ត

## សាធារណចេតសិក

***ន័យទី១*** ☞.សព្វចិត្តសាធារណចេតសិក ៧ មានផស្សៈជាដើម ប្រកបជាមួយចិត្តបានទាំងអស់ ៨៩ ឬ១២១ ដួង។

## សម្បយោគន័យបកណ្ណកចេតសិក

***ន័យទី១*** ☞.វិតក្កចេតសិក ប្រកបជាមួយចិត្តបាន ៥៥ ដួង ក្នុងចិត្តពិស្ដារ គឺៈ កាមាវចរចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណ ១០) និងបឋមជ្ឈានចិត្ត ១១ ។

*☞.មិនប្រកបជាមួយចិត្ត ៦៦ ដួង គឺៈ*

-ទ្វិបញ្ចវិញ្ញាណចិត្ត ១០

-ទុតិយជ្ឈានចិត្ត ១១ (លោកុត្តរចិត្ត៨+បឋមជ្ឈាន៣)

-តតិយជ្ឈានចិត្ត ១១

-ចតុត្ថជ្ឈានចិត្ត ១១

-បញ្ចមជ្ឈានចិត្ត២៣ (បញ្ចមជ្ឈាន១១+អរូបាវចរ ១២)

***ន័យទី២*** ☞.**វិចារចេតសិក** ប្រកបជាមួយចិត្ត
បាន ៦៦ ដួង ក្នុងចិត្តពិស្តារ គឺ:

-កាមាវចរចិត្ត៥៤(វៀរទ្វិបញ្ចវិញ្ញាណ១០)

-បឋមជ្ឈានចិត្ត១១

-ទុតិយជ្ឈានចិត្ត១១ ។

*☞.មិនប្រកបជាមួយចិត្ត ៥៥ ដួង គឺ:*

-ទ្វិបញ្ចវិញ្ញាណចិត្ត១០

-តតិយជ្ឈានចិត្ត១១

-ចតុត្ថជ្ឈានចិត្ត ១១

-បញ្ចមជ្ឈានចិត្ត២៣

***ន័យទី៣*** ☞.**អធិមោក្ខចេតសិក** ប្រកប
ជាមួយចិត្តបាន ៧៨ឬ១១០ដួង គឺ:

-កាមាវចរចិត្ត៤៣(វៀរទ្វិបញ្ចវិញ្ញាណ១០
និងវិចិកិច្ឆាសម្បយុត្តចិត្ត១)

-មហគ្គតចិត្ត ២៧

-លោកុត្តរចិត្ត៨ ឬ៤០ ដួង ។

*☞.មិនប្រកបជាមួយចិត្ត១១ដួងគឺៈ*

-ទ្វិបញ្ចវិញ្ញាណចិត្ត ១០

-វិចិកិច្ឆាសម្បយុត្តចិត្ត ១ ។

***ន័យទី៤*** ☞.**វិរិយចេតសិក** ប្រកបជាមួយចិត្តបាន៧៣ឬ១០៥ដួងគឺៈ

-កាមាវចរចិត្ត៣៨ (វៀរទ្វិបញ្ចវិញ្ញាណ១០ សន្តីរណចិត្ត៣ និងមនោធាតុចិត្ត៣)

-មហគ្គតចិត្ត ២៧

-លោកុត្តរចិត្ត៨ឬ៤០ ។

*☞.មិនប្រកបជាមួយចិត្ត១៦ដួងគឺៈ*

-ទ្វិបញ្ចវិញ្ញាណចិត្ត១០

-សន្តីរណចិត្ត៣

-មនោធាតុចិត្ត ៣ ។

***ន័យទី៥*** ☞.**បីតិចេតសិក** ប្រកបជាមួយចិត្ត បាន៥១ដួង ក្នុងចិត្តពិស្តារ គឺ:

-កាមាវចរសោមនស្សសហគតចិត្ត ១៨ (គឺ សោមនស្សលោភមូលចិត្ត៤ សោមនស្សសន្តីរណចិត្ត១ ហសិតុប្បាទចិត្ត១ និង សោមនស្សកាមាវចរសោភណចិត្ត ១២)

-បឋមជ្ឈានចិត្ត ១១

-ទុតិយជ្ឈានចិត្ត ១១

-តតិយជ្ឈានចិត្ត ១១ ។

*☞.មិនប្រកបជាមួយចិត្ត ៧០ ដួង គឺ:*

-ឧបេក្ខាលោភមូលចិត្ត ៤

-ទោសមូលចិត្ត ២

-មោហមូលចិត្ត ២

-មនោធាតុចិត្ត ៣

-មនោទ្វារាវជ្ជនចិត្ត ១

-ទ្វិបញ្ចវិញ្ញាណ ១០

-ឧបេក្ខាសន្តីរណចិត្ត ២

-ឧបេក្ខាកាមាវចរសោភណចិត្ត ១២

-ចតុត្ថជ្ឈានចិត្ត ១១

-បញ្ចមជ្ឈានចិត្ត ២៣ ។

***ន័យទី៦*** ☞.**ឆន្ទចេតសិក** ប្រកបជាមួយចិត្ត បាន៦៩ ឬ១០១ដូងគឺៈ

កាមាវចរចិត្ត៣៤ (វៀរមោហមូលចិត្ត២ និង អហេតុកចិត្ត១៨)

-មហគ្គតចិត្ត២៧

-លោកុត្តរចិត្ត៨ ឬ៤០ ។

☞.*មិនប្រកបជាមួយចិត្ត ២០ ដួងគឺៈ*

-មោហមូលចិត្ត២

-អហេតុកចិត្ត១៨ ។

# ចិត្តដែលបកិណ្ណកចេតសិក
# ប្រកបនិងមិនប្រកប

| ឈ្មោះចេតសិក | ប្រកបបាន | ប្រកបមិនបាន |
|---|---|---|
| វិតក្កចេតសិក | ៥៥ | ៦៦ |
| វិចារចេតសិក | ៦៦ | ៥៥ |
| អធិមោក្ខចេតសិក | ៧៨(១១០) | ១១ |
| វិរិយចេតសិក | ៧៣(១០៥) | ១៦ |
| បីតិចេតសិក | ១ | ៧០ |
| ឆន្ទចេតសិក | ៦៩(១០១) | ២០ |

# សម្បយោគន័យអកុសល
# ចេតសិក

***ន័យទី១*** ☞.មោចតុកចេតសិក គឺ មោហៈ អហិរកៈ អនោត្តប្បៈ ឧទ្ធច្ចៈ៤នេះ ប្រកបជាមួយ អកុសលចិត្តបានទាំង១២ដួង។

***ន័យទី២*** ☞.លោតិកចេតសិក គឺ លោភៈ ទិដ្ឋិ មានៈ ៣នេះ ប្រកបជាមួយលោភមូលចិត្តបាន តាមសមគួរ ៨ ដួងគឺៈ

-លោភចេតសិក ប្រកបក្នុងលោភមូលចិត្ត ៨

-ទិដ្ឋិចេតសិក ប្រកបទិដ្ឋិគតសម្បយុត្តចិត្ត ៤

-មានចេតសិក ប្រកបទិដ្ឋិគតវិប្បយុត្តចិត្ត៤

***ន័យទី៣*** ☞.ទោចតុកចេតសិក គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ៤នេះ ប្រកបជាមួយទោស-មូលចិត្ត ២ ដួង ។

***ន័យទី៤*** ☛.**ថីទុកចេតសិក** គឺ ថីនៈ មិទ្ធៈ ២ នេះ ប្រកបជាមួយអកុសលសសង្ខារិកចិត្ត ៥ដួង គឺៈ

-លោភមូលសសង្ខារិកចិត្ត ៤

-ទោសមូលសសង្ខារិកចិត្ត ១

***ន័យទី៥*** ☛.**វិចិកិច្ឆាចេតសិក** ១នេះ ប្រកបជាមួយតែវិចិកិច្ឆាសម្បយុត្តចិត្ត១ដួងប៉ុណ្ណោះ។

# សម្បយោគន័យសោភណា

# ចេតសិក

***ន័យទី១*** ☞.សោភណសាធារណចេតសិក ១៩ប្រកបជាមួយសោភណចិត្ត បានទាំងអស់ ៥៩ ឬ៩១ដួង គឺ:

-កាមាវចរសោភណចិត្ត ២៤

-មហគ្គតចិត្ត ២៧

-លោកុត្តរចិត្ត ៨ ឬ៤០ ។

***ន័យទី២*** ☞.**វិរតិចេតសិក** គឺ:សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ៣ នេះ ប្រកបជាមួយសោ-ភណចិត្តបាន ១៦ ឬ៤៨ ដួង គឺ:

-មហាកុសលចិត្ត៨

-លោកុត្តរចិត្ត៨ ឬ៤០។

*☞.មិនប្រកបជាមួយសោភណចិត្ត ៤៣ដួង គឺ:*

-មហាវិបាកចិត្ត៨

-មហាកិរិយាចិត្ត៨

-មហគ្គតចិត្ត២៧ ។

❋.វិរតិចេតសិកទាំង៣នេះ កាលណាប្រកបក្នុងលោកុត្តរចិត្ត រមែងប្រកបបានពិតប្រាកដហើយព្រមគ្នាទាំង៣ ក្នុងឋានៈជាអ្នកប្រហារមិច្ឆាវាចា មិច្ឆា-កម្មន្តៈ និងមិច្ឆាអាជីវៈ ជាសមុច្ឆេទ ។ ប៉ុន្តែកាលណាប្រកបក្នុងមហាកុសលចិត្តវិញ រមែងប្រកបបានមិនជាប្រាកដទេ ហើយមិនព្រមគ្នាទេ ព្រោះមានអារម្មណ៍ផ្សេងគ្នា ។

***ន័យទី៣*** **☞.អប្បមញ្ញាចេតសិក** គឺ ករុណា និងមុទិតា ២នេះ ប្រកបជាមួយសោភណចិត្តបាន ២៨ដួង គឺ:

-មហាកុសលចិត្ត៨

-មហាកិរិយាចិត្ត៨

-រូបាវចរចិត្ត ១២ (វៀររូបាវចរបញ្ចមជ្ឈានចិត្ត៣)

*☞.មិនប្រកបជាមួយសោភណចិត្ត៣១ឬ៦៣ដួងគឺ*

-អរូបាវចរឈានចិត្ត១២ -មហាវិបាក៨

-លោកុត្តរចិត្ត ៨ ឬ៤០ -បញ្ចមជ្ឈានរូបាវចរ៣

***ន័យទី៤*** ☞.**បញ្ញាចេតសិក** ប្រកបជាមួយសោភណចិត្តបាន ៤៧ឬ៧៩ដួង គឺៈ

-កាមាវចរសោភណញាណសម្បយុត្តចិត្ត១២

-មហគ្គតចិត្ត ២៧

-លោកុត្តរចិត្ត ៨ឬ៤០ដួង ។

*☞.មិនប្រកបជាមួយចិត្ត* ***១២ដួង*** ដែលជាកាមាវចរសោភណញាណវិប្បយុត្តចិត្ត។

# ពាក្យអធិប្បាយ




## 🕮.*លោភមូលចិត្ត ៨ ដួង*

មុននឹងយើងសិក្សាចិត្ត និងចេតសិក យើងត្រូវចាំឈ្មោះចិត្ត ឲ្យបានច្បាស់លាស់ជាមុនសិន បន្ទាប់មកយើងនឹងសិក្សាថា តើចេតសិកណាដែលប្រកបនឹងចិត្តណាខ្លះ?

*__ឧទាហរណ៍__* លោភដួងទី ១ ***សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ*** ឬដោយសង្ខេប **សោ. ទិសំ. អ.**ចុះចេតសិក ១៩ ។ យើងចង់ដឹងថា ចេតសិក ១៩ នោះ មានអ្វីខ្លះ ?

- បីតិ កើតតែជាមួយសោមនស្សវេទនា លោភដួងទី ១ ជាសោមនស្ស ត្រូវមានបីតិកើតជាមួយ អញ្ញសមានាចេតសិក ១៣ កើតគ្រប់ មិនវៀរមួយណាឡើយ ។

✸.បន្ទាប់មកយើងសិក្សា(មានមោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ ) ឈ្មោះ ថាសព្វាកុសលាយោគី ចេតសិក មកពី*សព្វ+អកុសល+យោគីចេតសិក* ប្រែថា ចេតសិក កើតទូទៅគ្រប់អកុសលចិត្តទាំង១២ ដួង ។

➢ លោតិកៈ៣ លោភោ ទិដ្ឋិ មានោ លោភចេតសិក កើតគ្រប់លោភមូលចិត្ត ទាំង ៨ ដួង ទិដ្ឋិចេតសិក កើតគ្រប់ទិដ្ឋិគតសម្បយុត្ត ៤ មានចេតសិក ដោយច្រើនកើតជាមួយនឹងទិដ្ឋិគតវិប្បយុត្ត ៤ ដួង ប៉ុន្តែពេលខ្លះក៏មិនមាន មានៈដែរ រួមទាំងអស់ជា ១៩ដួង គឺ អញ្ញសមានា១៣+មោចតុកៈ៤ +លោតិកៈ២ (វៀរមានៈចេតសិក ពីព្រោះ ដួងទី១ នេះជាទិដ្ឋិគតសម្បយុត្ត) ។




**លោភមូលចិត្តដួងទី ២** នេះ ដូចដួងទី ១ ដែរ ប៉ុន្តែខុសត្រង់សសង្ខារិក មានចេតសិកចុះ ២១ គ្រាន់តែថែម ថីទុកៈ ២ គឺ ថីនំ មិទ្ធំ ១៩+២ រួមជា ២១។

- ថីទុកៈ ២ ប្រភេទ កើតជាមួយនឹងចិត្តដែលជាសសង្ខារិក ។

***<u>ឧទាហរណ៍</u>*** បុគ្គលដែលឃើញផ្ទះ របស់ខ្លួនដែលធ្វើហើយថ្មី ៗ ក៏សប្បាយរីករាយ ជាសោមនស្សវេទនា មានទិដ្ឋិប្រកាន់ថា ជារបស់ខ្លួន កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំនេះជាដួងទី ១ ចំណែកដួងទី ២ ដោយមានអ្នកដទៃពោលសរសើរថា ផ្ទះរបស់អ្នកស្អាតណាស់ ទិដ្ឋិក៏កើតឡើងប្រកាន់ថាផ្ទះជារបស់ខ្លួន ហើយក៏រីករាយ ជាសោមនស្សវេទនា ដោយមានអ្នកដទៃបបួលដឹកនាំ ។




✷.**លោភដួងទី៣**នេះមានចេតសិកកើតរួមជាមួយ ១៩ ដូចលោភដួងទី ១ ដែរ ប៉ុន្តែលោភដួងទី ៣ នេះ ជាទិដ្ឋិគតវិប្បយុត្ត ១៩ ដកទិដ្ឋិ ១ សល់ ១៨ បូក មានៈ១ រួមជា ១៩ ដដែល ។




✷.**លោភដួងទី៤** នេះ មានចេតសិកចុះ ២១ ដូចនឹងដួងទី ៣ ដែរ ប៉ុន្តែបូកនឹងថីទុកៈ ២ ។

***ឧទាហរណ៍*** ក្នុងខណៈពេលដែលមាន មានៈ ឃើញខ្លួនឯងស្អាតជាងគេ ពេលនោះក៏រីករាយឡើងជាសោមនស្សវេទនា លើកតម្កើងខ្លួនឯង ជាមានៈ ហើយមិនមាន អ្នកដទៃបបួលដឹកនាំជាអសង្ខារិក ។

➢ ក្នុងខណៈដែលមិនមាន មានៈ ដូចជាឃើញព្រះចន្ទពេញវង់ ពេលនោះក៏រីករាយ ជាសោមនស្សវេទនា ហើយមិនបាន ប្រកាន់ព្រះចន្ទនោះជារបស់យើង ពេលនោះមិនមានមានៈ មានកម្លាំងខ្លាំងក្លា



ដោយមិនមានអ្នកដទៃបបួលដឹកនាំ ។ នេះជាដួងទី ៣ ចំណែកដួងទី ៤ គ្រាន់តែមាន អ្នកដទៃបបួលដឹកនាំ ។




✷.**លោភដួងទី៥** នេះ មានចេតសិក ១៨ ដូចដួងទី១ ដែរ ប៉ុន្តែដកបីតិចេតសិកចេញ ព្រោះជាឧបេក្ខាវេទនា ។




✷.**លោភដួងទី៦** នេះ មានចេតសិកចុះ ២០ដូចដួងទី២ដែរប៉ុន្តែវៀរបីតិ ។

***<u>ឧទាហរណ៍</u>*** ដូចដួងទី ១ និងដួងទី ២ ដែរ ប៉ុន្តែជាឧបេក្ខា ជាកណ្ដាល ដូចជាឃើញផ្ទះយូរៗទៅមិនរីករាយទេ ក៏ប៉ុន្តែមិនព្រមលះដែរ ។




✷.លោភដួងទី៧ នេះ មានចេតសិកចុះ ១៨ ដូចដួងទី៣ដែរប៉ុន្តែដកបីតិ។




✷.លោភដួងទី ៨ នេះ មានចេតសិកចុះ ២០ប្រភេទដូចដួងទី៤ដែរ ប៉ុន្តែដកបីតិ។

<u>*ឧទាហរណ៍*</u> ដូចដួងទី ៣ និងដួងទី ៤ ដែរ ប៉ុន្តែ ខុសត្រង់វេទនា ដូចជា ក្នុងខណៈឃើញព្រះចន្ទពេញវង់ យូរ ៗ ទៅ មិនមានការរីករាយទេ ។

### 🕮.***ទោសមូលចិត្ត ២ ដួង***




✷.ទោសមូលចិត្ត ដួងទី ១ នេះមានចេតសិកចុះ ២០ គឺអញ្ញសមានាចេតសិក ១២ (វៀរបីតិ) ព្រោះទោសចិត្តមិនមានការរីករាយទេ មោចតុកៈ ៤ ទោចតុកៈ ៤ រួមជា២០ ដួង ។




✷.ទោសដួងទី ២ នេះ មានចេតសិកចុះ ២២ ប្រភេទ ដូចដួងទី ១ ដែរ ប៉ុន្តែថែមថីទុកៈ ២ ។ដូចជាបុគ្គលដែលឮគេជេរ ក៏កើតការថ្នាំងថ្នាក់ឡើង ជាបដិឃសម្បយុត្ត កើតឡើងដោយមិនមានអ្នកដទៃបបួលដឹកនាំ នេះជា ទោសដួងទី ១ ចំណែកដួងទី ២ ខុសត្រង់ មានគេជេរដែរ ប៉ុន្តែមិន

បានឮដោយផ្ទាល់ មានអ្នកដទៃមកប្រាប់ ទោសៈក៏កើតឡើងជាសសង្ខារិក មានចំណុចច្រើនទៀត ។




### 🕮.មោហមូលចិត្ត ២ ដួង

✷.**ដួងទី ១** នេះមានចេតសិកចុះ ១៥ ប្រភេទ គឺអញ្ញសមានាចេតសិក ១០(វៀរបីតិ អធិ-មោក្ខៈឆន្ទៈ) មោចតុកៈ ៤ វិចិកិច្ឆា ១ ។




✷.**ដួងទី ២** នេះមានចេតសិកចុះ ១៥ ដែរ គឺអញ្ញសមានាចេតសិក ១១ (វៀរ បីតិ ឆន្ទៈ) មោចតុកៈ៤ ។ ***ឧទាហរណ៍*** សង្ស័យអ្វីមួយដូចជាសង្ស័យក្នុងគុណព្រះពុទ្ធ អធិមោក្ខៈ ការចុះចិត្តស៊ុប ឆន្ទៈ ការពេញចិត្ត បីតិ រីករាយក៏មិនមានចំណែកដួងទី ២ ដូចជាការរវើរវាយ អធិមោក្ខៈមានចុះស៊ុបក្នុងរឿងអ្វីមួយ ប៉ុន្តែមិនមានឆន្ទៈនិងបីតិទេ។

*ចប់អកុសលចិត្ត ១២ ដួង*

🕮🕮🕮

## ៦.អហេតុកចិត្ត ១៨ ដួង

⊙.ទ្វិបញ្ចវិញ្ញាណ១០(ចក្ខុវិញ្ញាណ សោត-វិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ x២ គឺកុសលវិបាក ១ អកុសលវិបាក១) ចុះចេតសិក ៧ ប្រភេទគឺ សព្វចិត្តសាធារណៈ ៧ ។

⊙.មនោធាតុ៣ដួង និងមនោវិញ្ញាណធាតុកុសលវិបាក ១ និងអកុសលវិបាក ១ ទាំង ៥ នេះ ចុះចេតសិក ១០ គឺអញ្ញសមានាចេតសិក ១០ (វៀរ បីតិ វីរិយៈ ឆន្ទៈ) ។

⊙.សោមនស្សមនោវិញ្ញាណធាតុ ដែលជាអហេតុកកុសលវិបាក១ ដួង ចុះចេតសិក១១ប្រភេទ គឺ អញ្ញសមានាចេតសិក១១(វៀរ វីរិយៈនិង ឆន្ទៈ) ។

⊙.ឧបេក្ខាមនោវិញ្ញាណធាតុ អហេតុកកិរិយា ១ដួង ចុះចេតសិក ១១ គឺ អញ្ញសមានាចេតសិក ១១(វៀរ បីតិ និង ឆន្ទៈ) ។

⊙.ហសិតុប្បាទចិត្ត ១ ដួង ចុះចេតសិក ១២ គឺ អញ្ញសមានាចេតសិក ១២ (វៀរ ឆន្ទៈ) ។

***<u>ចំណាំ</u>*** ឆន្ទៈ មិនកើតជាមួយ អហេតុកៈចិត្ត ១៨ដួងទេ ។

⊙.អហេតុកចិត្ត ១៨ ដួងនេះ ខ្ញុំមិនបាន ពន្យល់ឲ្យច្បាស់លាស់ទេ ព្រោះទាក់ទងនឹងវិថីចិត្ត បរិច្ឆេទទី ៤ ។

ចប់អហេតុកចិត្ត ១៨ ដួង




## ❋.មហាកុសលចិត្ត ៨ ដួង

➢.**ដួងទី១** នេះ ចុះចេតសិក ៣៨ គឺ អញ្ញសមានាចេតសិក១៣និងសោភណចេតសិក ២៥។




➢.**ដួងទី២** នេះ ចុះចេតសិក ៣៨ គឺៈ អញ្ញសមានាចេតសិក១៣ និងសោភណចេតសិក ២៥ ។




➢.**ដួងទី៣** នេះ ចុះចេតសិក ៣៧ គឺៈ អញ្ញសមានាចេតសិក ១៣ និង សោភណចេតសិក ២៤ (វៀរ បញ្ញា)។




➢.**ដួងទី៤** នេះ ចុះចេតសិក ៣៧ គឺៈ អញ្ញសមានាចេតសិក ១៣ និងសោភណចេតសិក ២៤ (វៀរបញ្ញា)។




➢.**ដួងទី៥** នេះ ចុះចេតសិក ៣៧ គឺ: អញ្ញសមានាចេតសិក ១២ (វៀរ បីតិ) និង សោភណចេតសិក ២៥ ។




➢.**ដួងទី ៦** នេះ ចុះចេតសិក ៣៧ គឺ: អញ្ញសមានាចេតសិក ១២ (វៀរ បីតិ) និង សោភណចេតសិក ២៥ ។




➢.**ដួងទី៧** នេះ ចុះចេតសិក ៣៦ គឺ: អញ្ញសមានាចេតសិក ១២ (វៀរ បីតិ) និង សោភណចេតសិក ២៤ (វៀរ បញ្ញា) ។




➢.**ដួងទី៨** នេះ ចុះចេតសិក ៣៦ គឺ: អញ្ញសមានាចេតសិក ១២ (វៀរ បីតិ) និង សោភណចេតសិក ២៤ (វៀរ បញ្ញា) ។

☞.**ដួងទី ៥.៦.៧.៨** ត្រូវវៀរ បីតិ ព្រោះជាឧបេក្ខា ។

☛.ដួងទី៣.៤.៧.៨ ត្រូវវៀរ បញ្ញា ព្រោះជាញាណវិប្បយុត្តចិត្ត ។

ចប់កុសលចិត្ត ៨ ដួង




## ❋.មហាវិបាកចិត្ត ៨ ដួង

➢.**ដួងទី១**នេះ ចុះចេតសិក៣៣ ប្រភេទ គឺអញ្ញសមានាចេតសិក ១៣និងសោភណចេតសិក ២០(វៀរ វិរតិ៣ និង អប្បមញ្ញា ២ ) ។




➢.**ដួងទី ២** នេះ ចុះចេតសិក ៣៣ គឺៈ អញ្ញសមានាចេតសិក ១៣ និងសោភ-ណចេតសិក ២០ ប្រភេទ(វៀរ វិរតិ៣ និង អប្បម-ញ្ញា ២) ។




➢.**ដួងទី ៣** នេះ ចុះចេតសិក ៣២ គឺៈ អញ្ញសមានាចេតសិក ១៣ និងសោភ-ណចេតសិក ១៩ ប្រភេទ(វៀរ វិរតិ ៣ អប្បមញ្ញា ២ និង បញ្ញា១) ។




➢.**ដួងទី ៤** នេះ ចុះចេតសិក ៣២ គឺៈ អញ្ញសមានាចេតសិក ១៣ និង សោភណចេតសិក ១៩ប្រភេទ(វៀរ វិរតិ ៣ អប្បមញ្ញា ២ និង បញ្ញា ១) ។




➢.**ដួងទី ៥** នេះ ចុះចេតសិក ៣២ គឺៈ អញ្ញសមានាចេតសិក ១២ (វៀរ បីតិ) និង សោភណចេតសិក ១៩ (វៀរ វិរតិ៣ និង អប្បមញ្ញា ២ ) ។




➢.**ដួងទី ៦** នេះ ចុះចេតសិក ៣២ គឺៈ អញ្ញសមានាចេតសិក ១២ (វៀរ បីតិ) សោភណចេតសិក ១៩ (វៀរ វិរតិ ៣ និង អប្ប-មញ្ញា ២ ) ។




➢.**ដួងទី ៧** នេះ ចុះចេតសិក ៣១ គឺៈ អញ្ញសមានាចេតសិក ១២ (វៀរ បីតិ) និង សោភណចេតសិក ១៩ ប្រភេទ(វៀរ វិរតិ៣ អប្បមញ្ញា ២ និង បញ្ញា ១) ។




